សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីការបោកខោអាវ។ ដែលការបោកខោអាវគឺមានពីររបៀប
របៀបទីមួយ គឺជាការបោកខោអាវដោយប្រើម៉ាស៊ីន របៀបទីពីរ គឺជាការបោកខោអាវដោយប្រើដៃ។
ប៉ុន្តែនៅក្នុងរូបភាពនេះ គឺជាការបោកខោអាវដោយប្រើដៃ[1]។

នៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់ គាត់ពាក់អាវយឺតពណ៌សដៃខ្លី
ជាមួយនឹងខោជើងវែងពណ៌ស។ គាត់បានដើរចូលទៅក្នុងបន្ទប់គេងរបស់គាត់
បន្ទាប់មកគាត់ក៏បានបើកទូខោអាវរបស់គាត់ ប៉ុន្តែយើងឃើញនៅក្នុងទូខោអាវរបស់គាត់
អត់មានខោអាវនៅសល់ទេ ដោយសារតែខោអាវរបស់គាត់ប្រឡាក់ និងគាត់មិនបានគក់
ឬក៏ប្រហែលជាគាត់ភ្លេចគក់ ដូច្នេះ ដូច្នេះអត់មានខោអាវនៅសល់នៅក្នុងទូសម្រាប់គាត់ទេ
យើងឃើញមានតែទំពក់ខោអាវព្យួរជាប់ជាមួយនឹងដែក នៅក្នុងទូខោអាវនោះ។
អញ្ចឹងយើងឃើញគាត់ឈរច្រត់ដៃទាំងពីរនៅលើចង្កេះរបស់គាត់
និងគាត់សម្លឹងមើលទៅក្នុងទូខោអាវ ដោយមិនមាន ដោយមិនមានខោអាវនៅសល់
ដោយមិនមានខោអាវព្យួរនៅសល់នៅក្នុងទូទេ អញ្ចឹងខោអាវទាំងអស់គឺប្រឡាក់។

រូបភាពទី ២ គាត់ក៏បានដើរចេញពីក្នុងបន្ទប់គេងរបស់គាត់ បន្ទាប់មកគាត់ក៏បានដើរមកក្នុង
គាត់ក៏បានដើរមកក្នុងបន្ទប់មួយទៀតដែលជាបន្ទប់ដាក់អីវ៉ាន់ និងជាបន្ទប់ដែលមាន
ដែលដាក់នូវម៉ាស៊ីន ម៉ាស៊ីនបោកខោអាវនៅខាងក្នុងនោះផងដែរ។
អញ្ចឹងនៅពេលដែលគាត់ដើរចូល គាត់ក៏បានឃើញខោអាវរបស់គាត់ ដាក់គរនៅក្នុងកន្ត្រក
នៅក្នុងកន្ត្រកមួយ ដែលកន្ត្រកនោះគឺដាក់នៅលើ
ដែលកន្ត្រកនោះគឺដាក់នៅលើតុនៅក្នុងបន្ទប់នោះ។ អញ្ចឹងយើងឃើញនៅក្នុងកន្ត្រកនោះ
គឺមានខោអាវរបស់ គឺមានខោអាវរបស់គាត់ជាច្រើនដាក់គរនៅក្នុងនោះ
ដែលខោអាវទាំងអស់នោះគឺជាខោអាវប្រឡាក់ ដែលមិនទាន់បាន ដែលគាត់មិនទាន់បានគក់
ដែលគាត់មិនបាន មិនទាន់បានគក់ ឬក៏មិនទាន់បានបោកវានៅឡើយទេ។
អញ្ចឹងគាត់ក៏បានដើរចូលទៅក្នុងបន្ទប់នោះ ដើម្បីប្រមូលខោអាវទាំងអស់នោះយកទៅដាក់
យកទៅដាក់គក់ក្នុងម៉ាស៊ីន ដូច្នេះគាត់ នៅពេលដែលគាត់បោកគក់ហើយ គាត់
គាត់អាចយកខោអាវទាំងអស់នោះដាក់ចូលទៅក្នុងទូរបស់គាត់វិញ។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣
ក្រោយពេលដែលគាត់ដើរមកឃើញខោអាវរបស់គាត់គរនៅក្នុងកន្ត្រកខោអាវជាច្រើន

[1] Actually, this illustration, recording and transcript is about doing the laundry using a washing machine.

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតគាត់ក៏បានយួរកន្ត្រកខោអាវនោះ ដើរតម្រង់ទៅកាន់ម៉ាស៊ីនបោកខោអាវ ដើម្បី
ម៉ាស៊ីនបោកខោអាវ ដើម្បីយកខោអាវទាំងអស់នោះ យកទៅបោក ឬក៏យកទៅគក់
ដោយយើងឃើញកន្ត្រកខោអាវនោះគឺមានដៃយួរ ដូច្នេះយើងឃើញដៃទាំងពីររបស់គាត់
គឺយួរសងខាង ដោយសារតែខោអាវរបស់គាត់ប្រឡាក់ច្រើន និងដាក់គរនៅក្នុងកន្ត្រកនោះ
ដូច្នេះគាត់ត្រូវកាន់ដៃពីរ អញ្ចឹងគាត់ត្រូវកាន់កន្ត្រកខោអាវនោះ ដោយប្រើដៃពីរ
អញ្ចឹងគាត់ដើរតម្រង់ទៅកាន់ទូ គាត់ដើរតម្រង់ទៅកាន់ម៉ាស៊ីនបោកខោអាវនោះ
ដើម្បីដាក់ខោអាវប្រឡាក់នោះចូលទៅខាងក្នុង ដើម្បីឲ្យម៉ាស៊ីននោះធ្វើការបោកគក់។
ដែលយើងឃើញនៅក្នុង នៅ ដែលយើងឃើញនៅលើម៉ាស៊ីនបោកខោអាវនោះ
យើងឃើញមានធ្នើរមួយ ដែលនៅលើធ្នើរនោះ យើងឃើញមានសាប៊ូ
និងប្រអប់សាប៊ូជាច្រើនទៀតដាក់នៅលើធ្នើរនោះ ដែលសាប៊ូទាំងអស់នោះគឺប្រើសម្រាប់
គឺជាសាប៊ូបោកខោអាវដែលប្រើសម្រាប់បោកខោអាវ
និងសាប៊ូខ្លះទៀតគឺជាសាប៊ូសម្រាប់ជូតសម្អាតឥដ្ឋ នៅក្នុងផ្ទះរបស់គាត់។
អញ្ចឹងបន្ទប់នោះគឺជាបន្ទប់ដែលដាក់សម្ភារៈ ដាក់សម្ភារៈសម្អាតបន្ទប់របស់គាត់ ដូចជាសាប៊ូ
និងមានដាក់ម៉ាស៊ីនបោកខោអាវនៅក្នុងនោះផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤
មុនពេលដែលគាត់ដាក់ខោអាវទាំងអស់នោះចូលទៅក្នុងម៉ាស៊ីន
គាត់ត្រូវបែងចែកខោអាវទាំងនោះជាពីរផ្នែកជាមុនសិន ដោយយើងឃើញនៅខាងស្ដាំដៃរបស់គាត់
គឺគាត់ដាក់ខោអាវពណ៌ស នៅខាងស្ដាំដៃ ដាក់ខោអាវពណ៌
ដាក់ខោអាវដែលមានពណ៌នៅខាងឆ្វេងដៃ ដោយសារតែខោអាវដែលមានពណ៌
នៅពេលដែលយើងធ្វើការបោកគក់ ខោអាវដែលមានពណ៌ខ្លះ គឺអាចចេញពណ៌
អញ្ចឹងនៅពេលដែលខោអាវនោះចេញពណ៌អាចធ្វើឲ្យ អាចធ្វើឲ្យប្រឡាក់អាវពណ៌សរបស់យើងបាន
ដូច្នេះយើងត្រូវបែងចែកជាពីរសិន ដើម្បីកុំឲ្យ
ដើម្បីចៀសវាងកុំឲ្យមានការចេញពណ៌ប្រឡាក់អាវពណ៌ស។
អញ្ចឹងយើងឃើញគាត់បានរើខោអាវចេញពី អញ្ចឹងគាត់បានរើខោអាវចេញពីកន្ត្រកខោអាវរបស់គាត់
ដោយយើងឃើញខោអាវរបស់គាត់មានច្រើន អញ្ចឹងយើងឃើញគាត់ដាក់ ដាក់អាវពណ៌សមួយដុំ
ដាក់អាវពណ៌មួយដុំ ដែលអាវពណ៌សនៅខាងស្ដាំដៃរបស់គាត់ អាវពណ៌នៅខាងឆ្វេងដៃរបស់គាត់។
អញ្ចឹងគាត់ត្រូវរៀបចំជាមុនសិន មុនពេលដាក់វាចូលទៅក្នុងម៉ាស៊ីនបោកខោអាវនោះ។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ ក្រោយពេលដែលគាត់បែងចែកខោអាវរបស់គាត់ជាពីរផ្នែក
ខោអាវពណ៌ និងខោអាវពណ៌សរួចរាល់ហើយ គាត់ក៏បានដើរទៅជិត គាត់ក៏បានដើរទៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានដើរទៅជិតម៉ាស៊ីនបោកខោអាវនោះ ដើម្បីបើកគម្រប ម៉ាស៊ីនបោកខោអាវនោះ
ដើម្បីដាក់ខោអាវចូលទៅខាងក្នុង ដើម្បីដាក់ខោអាវចូលទៅខាងក្នុង។
បន្ទាប់មកទៀតយើងឃើញក្រោយពេលដែលគាត់បើក បើកគម្រប បើកគម្រប
ម៉ាស៊ីនបោកខោអាវនោះហើយ
គាត់ក៏បានដាក់ខោអាវដែលប្រឡាក់នោះចូលទៅខាងក្នុងម៉ាស៊ីននោះ
ដើម្បីឲ្យម៉ាស៊ីននោះធ្វើការបោកគក់ ដើម្បីឲ្យម៉ាស៊ីននោះធ្វើការបោកសម្អាត
ឬក៏បោកគក់សម្អាតខោអាវរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៦ រូបភាពទី ៦ គាត់ក៏បានចាក់ម្សៅសាប៊ូចូលទៅក្នុងកែវមួយ ដែល ដែល
ដែលគាត់ ដែលគាត់ចាក់ម្សៅសាប៊ូចូលទៅក្នុងកែវនោះ ដើម្បីចាក់ចូលទៅក្នុងម៉ាស៊ីនបោកខោអាវ។
ដោយសារតែ ដោយសារតែគាត់ខ្លាចគាត់ចាក់ចូលទៅក្នុងម៉ាស៊ីនបោកខោអាវនោះជ្រុល
ពេលខ្លះយើងអាចចាក់ជ្រុលចូលទៅក្នុង ចូលទៅក្នុងម៉ាស៊ីនបោកខោអាវនោះ
ដូច្នេះគាត់ត្រូវចាក់ចូលទៅក្នុងកែវជាមុនសិន
ដើម្បីឲ្យច្បាស់ថាម្សៅសាប៊ូនោះគឺល្មមសម្រាប់បោកគក់ខោអាវរបស់គាត់។
អញ្ចឹងប្រសិនបើគាត់លើក លើក លើកដបសាប៊ូនោះចាក់ផ្ទាល់ចូលទៅក្នុង
ចាក់ផ្ទាល់ចូលទៅក្នុងម៉ាស៊ីនបោកខោអាវ ពេលខ្លះគាត់អាចចាក់ជ្រុល ពេលខ្លះគាត់អាចចាក់ជ្រុល
អញ្ចឹងគាត់ត្រូវចាក់ចូលទៅក្នុងកែវជាមុនសិន
ដើម្បីឲ្យប្រាកដថាម្សៅសាប៊ូនោះគឺល្មមសម្រាប់បោកគក់ខោអាវរបស់គាត់។

បន្ទាប់មកទៀតយើងឃើញរូបភាពទី ៧ រូបភាពទី ៧
គាត់ក៏បានចាក់ម្សៅសាប៊ូដែលមាននៅក្នុងកែវនោះ ចូលទៅក្នុងម៉ាស៊ីនបោកខោអាវ
ចូលទៅក្នុងម៉ាស៊ីនបោកខោអាវ បន្ទាប់មកទៀត គាត់ក៏បានបិទគម្រប ម៉ាស៊ីនបោកខោអាវនោះ
ដើម្បីឲ្យម៉ាស៊ីននោះធ្វើការបោកសម្អាតខោអាវរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ គាត់ក៏យកម្រាមដៃរបស់គាត់
គាត់ក៏បានយកចង្អុលដៃរបស់គាត់ទៅចុច គាត់ក៏បានយកចង្អុលដៃរបស់គាត់ ដើម្បីទៅចុចកុងតាក់
កុងតាក់នោះយើងឃើញ ជាកុងតាក់សម្រាប់ចាប់ផ្តើមឲ្យម៉ាស៊ីននោះដំណើរការ
អញ្ចឹងកុងតាក់ដើម្បីឲ្យម៉ាស៊ីននោះដំណើរការ
គាត់ក៏បានយកចង្អុលដៃរបស់គាត់ទៅចុចកុងតាក់នោះ
ដើម្បីឲ្យម៉ាស៊ីនបោកខោអាវនោះដំណើរការ។ អញ្ចឹងយើងឃើញការបោកខោអាវដោយប្រើ
ការបោកខោអាវដោយប្រើម៉ាស៊ីនគឺងាយស្រួល និងអាចសន្សំពេលបានច្រើន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែម៉ាស៊ីនធ្វើការបោកគក់លឿន
និងយើងគ្រាន់តែដាក់ខោអាវទាំងអស់នោះចូលទៅក្នុងម៉ាស៊ីន ម៉ាស៊ីននោះនឹងធ្វើការបោកគក់
នឹងធ្វើការបោកគក់ ដើម្បីសម្អាតខោអាវប្រឡាក់របស់យើង។ ប៉ុន្តែជាទូទៅនៅកម្ពុជាភាគច្រើន
ភាគច្រើនគឺយើងបោកគក់ខោអាវដោយប្រើដៃ ដោយប្រើដៃ ប៉ុន្តែគ្រួសារខ្លះ គឺគាត់
គឺគាត់ប្រើម៉ាស៊ីន ប៉ុន្តែមួយចំនួនធំគឺគាត់បោកគក់ដោយប្រើដៃ ជាពិសេស
គឺពិសេសគឺបងប្អូនខ្មែរយើងដែលគាត់រស់នៅជនបទ ឬក៏ស្រុកស្រែ
ភាគច្រើនគឺការបោកគក់របស់គាត់គឺប្រើដៃ។ អញ្ចឹងយើងឃើញគាត់ ឧបករណ៍របស់គាត់ដែលប្រើ
ដែលប្រើសម្រាប់បោកគក់ដោយប្រើដៃនោះ យើងឃើញគាត់មាន គាត់មានកន្ទន់មួយ
គាត់មានកន្ទន់មួយ ដែលកន្ទន់នោះ ពេលខ្លះគឺកន្ទន់ជ័រ ឬក៏ពេលខ្លះគឺ គឺកន្ទន់ដែក
ដែលកន្ទន់នោះគឺយើងប្រើសម្រាប់ដាក់ទឹក
សម្រាប់ទឹកក៏នឹងយើងចាក់ម្សៅសាប៊ូចូលទៅក្នុងកន្ទន់នោះ និងដាក់ខោអាវចូលទៅខាងក្នុង។
អ្នកខ្លះគឺគាត់ដាក់ត្រាំខោអាវនោះមួយសន្ទុះសិនជាមួយនឹងម្សៅសាប៊ូ ដើម្បីឲ្យម្សៅសាប៊ូនោះកាត់
កាត់នូវ នូវ កាត់នូវភាពកខ្វក់ ឬក៏ប្រឡាក់ ដែលជាប់នៅនឹងខោអាវរបស់យើង ដូច្នេះគឺយើងធ្វើការ
បន្ទាប់ពីយើងត្រាំវាមួយសន្ទុះហើយ គឺយើងងាយស្រួលក្នុងការបោកគក់។
ប៉ុន្តែអ្នកខ្លះគឺគាត់គ្រាន់តែដាក់ទឹក និងម្សៅសាប៊ូចូល អញ្ចឹងគាត់អត់ត្រាំវាទេ គឺគាត់បោកវាតែម្តង។
អញ្ចឹង យើង យើងមានច្រាសមួយ យើងមានច្រាសមួយ ដើម្បីគក់សម្អាតខោអាវទាំងអស់នោះ។
នៅពេលដែលយើងយកច្រាសមករុះ ឬក៏មកដុសសម្អាតខោអាវរបស់យើងដែលមាន
ដែលមានស្នាមប្រឡាក់ ឬក៏កខ្វក់ទាំងអស់នោះហើយ បន្ទាប់មកយើងប្រើដៃទាំងពីរញីវា
ដើម្បីឲ្យខោអាវទាំងនោះស្អាត ដើម្បីឲ្យខោអាវទាំងនោះអស់ក្អែល ឬក៏អស់ អស់
ឬក៏ឲ្យខោអាវទាំងនោះ គឺអស់នូវភាព អស់នូវស្នាមប្រឡាក់ទាំងអស់ ដែលមានជាប់នៅ
ដែលមានជាប់នៅ នៅលើខោអាវនោះ ដើម្បីសម្អាតវាឲ្យស្អាត។ អញ្ចឹងយើង ទីមួយ
ដំបូងគឺយើងត្រូវដាក់ទឹក បន្ទាប់មកគឺយើងដាក់ យើងដាក់ទឹកចូលទៅក្នុងកន្ទន់
បន្ទាប់មកទៀតគឺយើងដាក់ខោអាវចូលទៅក្នុង និងដាក់ម្សៅសាប៊ូ និងដាក់ម្សៅសាប៊ូ
អញ្ចឹងបន្ទាប់មកទៀត គឺយើងប្រើច្រាស យើងប្រើច្រាស ប្រើច្រាស ដើម្បី ដើម្បីរុះ
ឬក៏ដើម្បីដុសនូវស្នាមប្រឡាក់ដែលមាននៅលើខោអាវនោះ បន្ទាប់មកទៀតគឺយើងញីវា គឺយើងញីវា
និងនៅពេលដែលយើងញីជាមួយនឹងសាប៊ូរួចរាល់ហើយ គឺយើងដាក់ចូល
គឺយើងដាក់ចូលទៅក្នុងទឹកដែលអត់មានសាប៊ូ ដើម្បីលាងសម្អាត ដើម្បីលាង[សម្អាត]
ដើម្បីលាងសម្អាតសាប៊ូនោះឲ្យជ្រះ។ អញ្ចឹង ជាទូទៅ អ្នកខ្លះគឺគាត់ ក្រោយពីទឹកសាប៊ូ
បន្ទាប់មកគឺគាត់គក់សម្អាតជាមួយនឹងទឹកធម្មតាពីរដងទៀត
អ្នកខ្លះគឺគាត់គក់ជាមួយនឹងទឹកធម្មតាមួយដងទៀតតែប៉ុណ្ណោះ។
អញ្ចឹងអាស្រ័យទៅលើអ្នកខ្លះគឺគាត់ ដូចជានៅតាមស្រុកស្រែជនបទ ខ្លះគឺគាត់អត់សូវសម្បូរទឹក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះគឺគាត់ប្រើសន្សំសំចៃ ដូច្នេះការបោកគក់របស់គាត់ គឺគាត់ដាក់ម្សៅសាប៊ូបន្តិចបន្តួច
បន្ទាប់មកគាត់ជម្រះជាមួយនឹងទឹកស្អាត ឬក៏ទឹកធម្មតាយើងហ្នឹង ប្រហែលជាមួយដង មួយដង
អញ្ចឹងគាត់ដាក់ហាល គឺគាត់ដាក់ហាល។ អញ្ចឹងការ ការបោកខោអាវដោយប្រើដៃ
ការបោកខោអាវដោយប្រើដៃពេលខ្លះគឺចំណាយពេលយូរ
និងពេលខ្លះយើងអាចធ្វើឲ្យដៃរបស់យើងឈឺ ដោយសារតែយើងប្រើកម្លាំងដៃរបស់យើង
ដើម្បីរុះច្រាសបោកសម្អាត ដើម្បីរុះច្រាសបោកខោអាវ បោកសម្អាតកន្លែងដែលប្រឡាក់
ដែលមាននៅលើខោអាវរបស់យើងនោះ អញ្ចឹងពេលខ្លះការបោកខោអាវដោយប្រើដៃ
គឺចំណាយពេលយូរ និងធ្វើឲ្យយើងមានការឈឺ ឈឺដៃ ឈឺដៃ
និងពេលខ្លះដោយសារតែយើងអង្គុយយូរ ពេលខ្លះក៏មានការឈឺខ្នង ឬក៏ឈឺចង្កេះផងដែរ។
ដូច្នេះការបោកខោអាវដោយប្រើដៃ និងការបោកខោអាវដោយប្រើម៉ាស៊ីន
ការបោកខោអាវដោយប្រើម៉ាស៊ីន គឺចំណាយពេល គឺចំណាយពេលលឿនជាង
គឺចំណាយពេលលឿន និងស្រួលជាងការបោកខោអាវដោយប្រើដៃ។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ ក្រោយពេលដែលគាត់
ក្រោយពេលដែលគាត់បានចុចកុងតាក់ដោយប្រើ ក្រោយពេលដែលគាត់ចុចកុងតាក់
ទៅលើកុងតាក់ដែលចាប់ផ្តើមនោះ យើងឃើញ យើងឃើញទ្រនិចនាឡិកា ចំណាយពេល
យើងឃើញទ្រនិចនាឡិកាចង្អុលទៅកាន់លេខ ៩ ដែលមានន័យថា គាត់បានចំណាយពេល ៤៥
នាទី គាត់បានចំណាយពេល ៤៥ នាទី ដើម្បីឲ្យម៉ាស៊ីននោះធ្វើការបោកសម្អាត ធ្វើការបោកសម្អាត
បោកសម្អាតខោអាវដែល[ប្រឡាក់] ខោអាវរបស់គាត់ដែលប្រឡាក់ទាំងអស់នោះ។
អញ្ចឹងយើងឃើញទ្រនិចនាឡិកាចង្អុលទៅកាន់ម៉ោង ៩ ដែលគាត់ចំណាយពេល ៤៥ នាទី។

បន្ទាប់មកទៀត បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ ក្រោយពេលដែលគាត់រង់ចាំ ៤៥ នាទី
ដើម្បីឲ្យម៉ាស៊ីនបោកខោអាវនោះធ្វើការបោកសម្អាតខោអាវរបស់គាត់រួចរាល់ហើយ
គាត់ក៏បានបើកគម្រប [ខោអាវ] គាត់ក៏បានបើកគម្រប ម៉ាស៊ីន ម៉ាស៊ីននោះ
ដើម្បីយកខោអាវចេញមកខាងក្រៅ។ អញ្ចឹងយើងឃើញនៅពេលដែលគាត់បើកគម្រប
ម៉ាស៊ីននោះរួចរាល់ហើយ គាត់ក៏បានប្រមូលខោអាវទាំងអស់នោះ
ដែលមាននៅក្នុងម៉ាស៊ីនបោកគក់នោះ គាត់ក៏បានប្រមូលដាក់ចូលទៅក្នុងកន្ត្រកខោអាវ
ដើម្បីយកខោអាវទាំងអស់នោះមកហាលនៅខាងក្រៅ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី [១០] រូបភាពទី ១១
ក្រោយពេលដែលគាត់ប្រមូលខោអាវចេញពីម៉ាស៊ីនបោកខោអាវនោះ ប្រមូលអស់ហើយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានដើរ គាត់ក៏បានយួរកន្ត្រកខោអាវ ដែលមានដាក់ខោអាវទទឹកទាំងអស់នោះ
ដែលដាក់ខោអាវទទឹកទាំងអស់នោះ ដើម្បីយកវាមកហាល ដើម្បីយកវាមកហាល។
អញ្ចឹងយើងឃើញខោអាវរបស់គាត់ច្រើន អញ្ចឹងគឺគាត់ដាក់នៅក្នុងកន្ត្រក
អញ្ចឹងយើងឃើញមានច្រើន អញ្ចឹងការគក់ខោអាវដោយប្រើម៉ាស៊ីន បើទោះបីជា
បើទោះបីជាខោអាវច្រើន ពេលខ្លះគឺវាលឿនជាង លឿនជាងការបោកគក់ដោយប្រើដៃ។
ប៉ុន្តែប្រសិនបើការបោក ប្រសិនបើ ប្រសិនបើយើងធ្វើការបោកគក់ដោយប្រើដៃវិញ
និងខោអាវរបស់យើងច្រើន ពេលខ្លះយើងចំណាយពេលយូរ ពេលខ្លះយើងចំណាយពេលយូរ។
អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពនេះ គឺគាត់ចំណាយពេលតែ ៤៥ នាទី និងគាត់មិនបាន
គាត់មិនចាំបាច់បោកគក់ដោយប្រើដៃ គាត់គ្រាន់តែដាក់ខោអាវទាំងនោះចូលទៅក្នុងម៉ាស៊ីន
បន្ទាប់មកគាត់អង្គុយចាំតែ ៤៥ នាទី អញ្ចឹងគាត់អាចយកខោអាវទាំងអស់នោះយកមកហាលបាន។
អញ្ចឹងយើងឃើញរូបភាពទី ១១ គាត់យកខោអាវនោះ
ដែលខោអាវទាំងអស់នោះគាត់ដាក់នៅក្នុងកន្ត្រក ខោអាវ
អញ្ចឹងគាត់បានយកមកហាលនៅខាងក្រៅ។

បន្ទាប់មកយើងឃើញរូបភាពទី ១២ គាត់ក៏បានយកខោអាវទាំងអស់នោះយកមកហាល
យកមកហាល យើងឃើញខោអាវនោះមានហូរទឹកស្រក់ធ្លាក់ចុះមកខាងក្រោម ដោយសារតែ
ដោយសារតែខោអាវរបស់គាត់ទទឹក អញ្ចឹងយើងឃើញមាន មានទឹក
យើងឃើញមានទឹកស្រក់ធ្លាក់ចុះមកខាងក្រោម អញ្ចឹងយើងឃើញគាត់
យើងឃើញគាត់ហាលម្តងមួយៗនៅលើស្នួរខោអាវរបស់គាត់។ បន្ទាប់មកទៀត
ក្រោយពេលដែលគាត់ដាក់ហាលខោអាវទាំងអស់ នៅលើស្នួរខោអាវរបស់គាត់រួចរាល់ហើយ
គាត់ក៏បានដើរចូលមកក្នុងផ្ទះរបស់គាត់វិញ បន្ទាប់មកគាត់ក៏បានអង្គុយនៅលើសាឡុង
ឬក៏កៅអីនៅក្នុងបន្ទប់របស់គាត់។ អញ្ចឹងគាត់ក៏បានយកទូរស័ព្ទយកមកចុច ប្រហែលជាគាត់ឆាត
ឬក៏គាត់ផ្ញើសារជាមួយនឹង គាត់ឆាតជាមួយនឹងពួកម៉ាករបស់គាត់ ឬក៏ផ្ញើសារទៅពួកម៉ាករបស់គាត់
អញ្ចឹងក្នុងអំឡុងពេលដែលគាត់កំពុងតែរង់ចាំ ដើម្បីឲ្យខោអាវរបស់គាត់ស្ងួតនោះ
អញ្ចឹងគាត់បានមកអង្គុយ និងចុចទូរស័ព្ទ ដែលយើងឃើញទូរស័ព្ទគឺនៅក្នុងដៃរបស់គាត់។
អញ្ចឹងយើងឃើញ អញ្ចឹងពេលខ្លះ ពេលខ្លះ នៅពេលដែលយើងអង្គុយរង់ចាំយូរ
ពេលខ្លះយើងមានអារម្មណ៍ថាធុញ ប៉ុន្តែនៅពេលដែលយើងប្រើទូរស័ព្ទ
ឬក៏នៅពេលដែលយើងចុចទូរស័ព្ទលេងជាមួយនឹងពួកម៉ាក ដោយយើងឆាតជាមួយនឹងពួកម៉ាក
ឬក៏ផ្ញើសារលេងជាមួយពួកម៉ាក ពេលខ្លះការរង់ចាំយូរហាក់បីដូចជាមួយភ្លែត
ដោយសារតែពេលខ្លះយើងលេងជាមួយនឹងទូរស័ព្ទ យើង យើងលេងជាមួយទូរស័ព្ទភ្លេចខ្លួន
អញ្ចឹងការរង់ចាំគឺមួយភ្លែត ប៉ុន្តែប្រសិនបើ ប្រសិនបើយើងអង្គុយរង់ចាំដោយអត់មានទូរស័ព្ទ គ្រាន់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើង អត់មានទូរស័ព្ទ គឺគ្រាន់តែអង្គុយរង់ចាំ ពេលខ្លះគឺ គឺយើងមានអារម្មណ៍ថាយូរ
គឺមានអារម្មណ៍ថាយូរ។ អញ្ចឹងដោយសារតែគាត់ ដោយសារតែគាត់ ដោយ[សារ]
ដោយសារតែគាត់រង់ចាំឲ្យខោអាវរបស់គាត់ស្ងួត
និងដើម្បីគាត់សាយកមកទុកនៅខាងក្នុងផ្ទះរបស់គាត់វិញ អញ្ចឹងគាត់ក៏បានចុចទូរស័ព្ទអង្គុយលេង
នៅលើកៅអីក្នុងបន្ទប់របស់គាត់។ បន្ទាប់មកក្រោយពេលដែលគាត់លេងជាមួយនឹង [...]
ក្រោយពេលដែលគាត់លេងជាមួយនឹងពួកម៉ាករបស់គាត់មួយសន្ទុះធំហើយ
គាត់ក៏បានចេញមកខាងក្រៅ ដើម្បីស្ទាបខោអាវរបស់គាត់ ដើម្បីយកខោអាវណាដែលស្ងួត យកទៅ
យកចូលទៅក្នុងផ្ទះរបស់គាត់ ដើម្បីបត់វា ឬក៏ព្យួរវានៅក្នុងទូខោអាវរបស់គាត់វិញ។
អញ្ចឹងយើងឃើញគាត់ យើងឃើញគាត់ដើរចេញមកខាងក្រៅមកកាន់ស្នូខោអាវរបស់គាត់
អញ្ចឹងយើងឃើញគាត់សាខោអាវម្ដងមួយៗ គាត់ស្ទាបខោអាវណាដែលស្ងួតគាត់យក
គាត់ដាក់ចូលទៅក្នុងកន្ត្រកខោអាវរបស់គាត់ ដើម្បីយកមកបត់នៅខាងក្នុងផ្ទះរបស់គាត់
ខោអាវណាដែលមិនទាន់ស្ងួត គឺគាត់ដាក់ គឺគាត់នៅតែដាក់ហាលនៅ នៅលើស្នូខោអាវរបស់គាត់
រង់ចាំដើម្បីឲ្យវាស្ងួតទើបយកមកខាងក្នុងផ្ទះ។ អញ្ចឹងយើងឃើញគាត់សាខោអាវរបស់គាត់
ដោយដៃម្ខាងគាត់សាខោអាវ ដៃម្ខាងទៀតគឺគាត់កាន់ខោអាវ។ អញ្ចឹងដៃម្ខាងកាន់ ឬក៏ឱបខោអាវ
ដៃម្ខាងទៀតគឺគាត់សាខោអាវ ដែលខោអាវទាំងអស់នោះគឺ ដោយខោអាវទាំងអស់នោះគឺស្ងួត
គឺស្ងួតអស់ហើយ។

បន្ទាប់មកទៀត បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥
ក្រោយពេលដែលគាត់សាខោអាវដែលស្ងួតនោះចូលមកក្នុងផ្ទះរបស់គាត់
គាត់ក៏បានបត់ខោអាវនោះឲ្យមានរបៀប ដើម្បីដាក់ចូលទៅក្នុងទូខោអាវរបស់គាត់វិញ។
អញ្ចឹងយើងឃើញគាត់បត់ខោអាវម្ដងមួយៗ និងដាក់ខោអាវនោះគរលើគ្នា
និងដាក់ខោអាវនោះគរលើគ្នា។ អញ្ចឹងខោអាវខ្លះគឺគាត់បត់ ខោអាវខ្លះគឺគាត់ទុកសម្រាប់ព្យួរ។
ដោយសារតែខោអាវរបស់គាត់ ដោយសារតែខោអាវខ្លះ គឺ នៅពេលដែលបត់គឺមានភ្លីះច្រើន
ដូច្នេះពិបាក នៅពេលដែល នៅពេលដែលមានភ្លីះច្រើន នៅពេលដែលយើងពាក់ទៅ
គឺមើលទៅគឺវាអត់សូវស្អាត អញ្ចឹងយើងត្រូវព្យួរវា។ អញ្ចឹងខោអាវខ្លះ ដូចជាខោអាវយឺត
ពេលខ្លះយើង យើងគ្រាន់តែបត់វា និងដាក់ចូលទៅក្នុងទូជាការស្រេច។ អញ្ចឹងខោអាវខ្លះយើងបត់
ខោអាវខ្លះគឺយើងត្រូវការព្យួរ យើងត្រូវការព្យួរវា។

បន្ទាប់មកទៀតរូបភាពទី ១៦ រូបភាពទី ១៦ ក្រោយពេលដែលគាត់បត់ខោអាវរួចរាល់ហើយ
អញ្ចឹងខោអាវដែលគាត់ត្រូវការព្យួរ គាត់ក៏បានយកទៅព្យួរ ដោយប្រើទំពក់ខោអាវ ដែលមាននៅក្នុង
ដែលមាននៅក្នុងទូខោអាវនោះស្រាប់ អញ្ចឹងគាត់បានយកទំពក់ខោអាវនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យកមកព្យួរអាវរបស់គាត់ដាក់ចូលទៅក្នុងទូ ដាក់ចូលទៅកន្លែងដដែលវិញ។ 
អញ្ចឹងនៅទីបំផុតខោអាវដែលគាត់ប្រឡាក់ គាត់បានធ្វើការបោកសម្អាតដោយប្រើម៉ាស៊ីន 
និងខោអាវទាំងនោះគឺ ខោអាវទាំងនោះគឺបោកសម្អាតយ៉ាងស្អាត និងគាត់បានបត់ 
និងព្យួរវាយ៉ាងមានរបៀប ដាក់ចូលមកក្នុងទូនៅកន្លែងដើមវិញ។ 
ដូច្នេះការបោកគក់ដោយប្រើម៉ាស៊ីន គឺយើងអាចសន្សំពេល គឺយើងអាចសន្សំពេល និង 
និងមិនចំណាយកម្លាំង ប៉ុន្តែប្រសិនបើការបោកគក់ដោយប្រើដៃ គឺយើងចំណាយពេលយូរ 
និងយើងចំណាយកម្លាំងរបស់យើង ដោយសារតែយើង ដោយសារតែយើងប្រើច្រាស 
ដើម្បីយកមករុះ យើង ដោយសារតែយើងប្រើដៃរបស់យើងកាន់ច្រាស ដើម្បីយកច្រាសនោះមករុះ 
ឬក៏មកដុសសម្អាតខោអាវកខ្វក់នៅលើអាវរបស់យើង។ អញ្ចឹងការបោកខោអាវដោយប្រើ 
ដោយប្រើដៃ គឺចំណាយពេលយូរណាស់ និងការបោកខោអាវដោយប្រើម៉ាស៊ីន គឺសន្សំពេលវេលា 
និង និងមិនចំណាយកម្លាំងច្រើន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.